**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ACCOUNTING AND AUDITING REGULATOR

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ..០០១..........ន.គ.ស .ណ.ណ.ន.

ថ្ងៃព្រហស្បតិ៍ ១០រោចខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២២

# សេចក្ដីណែនាំ

## ស្ដីពី

## ការដាក់លិខិតជូនដំណឹងសម្រាប់ការប្រើប្រាស់ភាសាអង់គ្លេស ក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬ ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មកនិយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់សហគ្រាសទាំងអស់មេត្តាជ្រាបថា៖ ដើម្បីអនុវត្តសារាចរណែនាំលេខ ០០៩ សហវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ស្ដីពី**"ការប្រើប្រាស់ភាសា និងរូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ"** របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **និយ័តករគណនេយ្យនិងសវនកម្ម** សូមធ្វើការណែនាំដូចខាងក្រោម៖

១. សហគ្រាសដែលបានចុះបញ្ជីផ្លូវការរួចហើយ ត្រូវធ្វើការជូនដំណឹងអំពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មកនិយ័តករគណនេយ្យនិងសវនកម្ម ចាប់ពីថ្ងៃចេញសេចក្ដីណែនាំនេះ រហូតដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ជាកំហិត។ សម្រាប់សហគ្រាសដែលទើបបង្កើតថ្មី ត្រូវធ្វើការជូនដំណឹងអំពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រនិង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មកនិយ័តករគណនេយ្យនិងសវនកម្ម មិនឱ្យហួសរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលសហគ្រាសបានចុះបញ្ជីជាស្ថាពរជាមួយអគ្គនាយកដ្ឋានពន្ធដារ។

២. សហគ្រាសត្រូវប្រើប្រាស់ប្រព័ន្ធអនឡាញ (E-Filling System) របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនលិខិតជូនដំណឹងសម្រាប់ការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រនិង/ឬ ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធតាមគំរូលិខិតដែលបានផ្ដល់ជូនក្នុងប្រព័ន្ធស្រាប់។

៣. សហគ្រាសត្រូវអនុវត្តតាមការណែនាំជាជំហានៗដូចខាងក្រោម ដើម្បីដាក់លិខិតជូនដំណឹងមក **ន.គ.ស.**៖

**ជំហានទី១**៖សហគ្រាសត្រូវបង្កើតគណនីនៅលើប្រព័ន្ធ E-Filling របស់ **ន.គ.ស.** ដើម្បីអាចប្រើប្រាស់មុខងារជូនដំណឹងនេះបាន (ប្រសិនបើសហគ្រាសរបស់លោកអ្នកធ្លាប់មានគណនីប្រើប្រាស់ប្រព័ន្ធ E-Filling របស់ **ន.គ.ស.** រួចហើយ សូមប្រើប្រាស់គណនីដែលមានស្រាប់)។

**ជំហានទី២**៖សហគ្រាសត្រូវបំពេញព័ត៌មានទូទៅជាមុនសិន (សម្រាប់សហគ្រាសដែលទើបបង្កើតគណនីថ្មីនៅលើប្រព័ន្ធ E-Filling) រួចរក្សាទុក។

**ជំហានទី៣**៖សូមចុចលើមុខងារ "ជូនដំណឹងអំពីការប្រើប្រាស់ភាសា" ដែលមាននៅលើប្រព័ន្ធ E-Filling របស់ **ន.គ.ស.** បន្ទាប់មកសូមបំពេញព័ត៌មានបន្ថែម និងទាញយកទម្រង់លិខិតជូនដំណឹង ដើម្បីបំពេញព័ត៌មានអំពីការប្រើប្រាស់ភាសា ដោយបញ្ជាក់ពីឈ្មោះប្រព័ន្ធ ឈ្មោះក្រុមហ៊ុននិងប្រទេសផលិត និងភាសាប្រើប្រាស់ក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រតាមគំរូលិខិតរបស់ **ន.គ.ស.** រួចសូមបញ្ជូនលិខិតនោះមកវិញតាមប្រព័ន្ធ E-Filling ជាការស្រេច។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

សហគ្រាសត្រូវរក្សាទុកលិខិតជូនដំណឹងច្បាប់ដើមឱ្យបានត្រឹមត្រូវនៅទីតាំងសហគ្រាសរបស់ខ្លួន សម្រាប់ការត្រួតពិនិត្យអនុលោមភាពពី **ន.គ.ស.** នៅពេលក្រោយ។

សហគ្រាសណាដែលប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ ឬក្នុងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត ដោយមិនបានដាក់លិខិតជូនដំណឹងមក និយ័តករគណនេយ្យនិងសវនកម្ម តាមពេលវេលាដូចបានកំណត់ខាងលើ នឹងត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យ លេខ៧៩ អនុក្រ.បក.ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្ដីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម។

អាស្រ័យហេតុនេះ សូមម្ចាស់សហគ្រាសទាំងអស់ មេត្តាជ្រាប និងអនុវត្តតាមសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយក**

**ច្ចី ថារិត**

**ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម**
**សូមចូលរួមក្នុង Telegram Channel របស់**
**និយ័តករគណនេយ្យនិងសវនកម្ម**

**Kingdom of Cambodia**
**Nation Religion King**

**Accounting and Auditing Regulator**
No: 001 AAR S.N.N

Phnom Penh, 27 January 2022

# Instruction
# On
# Submission of Notice for Use of English Language in Computerized Accounting System and/or Other Related Computerized Systems to the Accounting and Auditing Regulator

The **Accounting and Auditing Regulator** of the **Non-Bank Financial Services Authority** would like to inform all owners of enterprises that to comply with Circular 009 MoEF dated 01 September 2021 on "**Use of Language and Currency in Accounting Records and Financial Statements**" of the Ministry of Economy and Finance, the **Accounting and Auditing Regulator (AAR)** would like to give an instruction as follows:

1. Any enterprise that has been officially registered already must give notice of use of English language in the computerized accounting system and/or other related computerized systems to the Accounting and Auditing Regulator from the date of this Instruction until **31 March 2022** without fail. For new enterprises, notice of use of English language in the computerized accounting system and/or other related computerized systems must be given to the Accounting and Auditing Regulator no later than 60 (sixty) days from the date that the enterprise is officially registered with the General Department of Taxation.
2. The enterprise must use E-Filing system of the **AAR** to submit the notice of use of language in computerized accounting system and/or other related computerized systems as per the sample letter provided in the system.
3. The enterprise must follow the following steps for submitting notice to the **AAR**:
   **Step 1**: The enterprise must create an account in the E-Filing system of the **AAR** in order to use functions of giving notice (if your enterprise has already had an account in the E-Filing system of the **AAR**, please use the existing account).
   **Step 2**: The enterprise must complete general information first (for enterprises that have just created a new account in the E-Filing system) and then save it.
   **Step 3**: Click the function "Give notice of use of language" in the E-Filing system of the **AAR** and then complete more information and download the form of giving notice and complete information about use of language by specifying the name of system, name of company and country that produces it and language used in the computerized accounting system as per the sample letter of the **AAR**, then send the letter back via the E-Filing.

The enterprise must properly keep the original notice letter in the enterprise for inspection of compliance from the **AAR** later.

Any enterprise using English language in the computerized accounting system and/or in other related accounting systems without giving notice to the Accounting and Auditing Regulator by the above deadline will be subject to penalties as stipulated in Sub-decree 79 OrNKr.BK dated 01 June 2020 on Interim Fines for Violations of Law on Accounting and Audit.

GARMENT MANUFACTURERS

In this regard, please all enterprise owners be informed and comply with this instruction in a highly effective manner.

**Director General**
(signed and stamped)
**Bou Tharin**

To get updated information on accounting and audit profession and field, please join the Telegram Channel of the **Accounting and Auditing Regulator**

**柬埔寨王国**

**民族 宗教 君主**

**会计与审计监管机构**

编号: 001 AAR S.N.N

金边，2022 年 1 月 27 日

**向会计与审计监管机构提交计算机化会计系统和/或其他相关计算机化系统中通知使用英语的指示**

**非银行金融服务管理局会计与审计监管机构**谨通知所有企业业主遵守财经部 2021 年 9 月 1 日签发的 009 号关于"**在会计记录和财务报表中使用语言和货币**"通知，会计与审计监管机构（AAR）兹给出如下指示：

1. 任何已正式注册的企业须自本指示签发之日起至 **2022 年 3 月 31 日**期间，向会计与审计监管机构提交在计算机化会计系统和/或其他相关计算机化系统中使用英语的通知。 对于新企业，须在企业正式在税务总局注册之日起 60（六十）天内向会计与审计监管机构提交在计算机化会计系统和/或其他相关计算机化系统中使用英语的通知。
2. 企业须使用**会计与审计监管机构（AAR）**的电子申报系统，按照系统提供的样本信函提交电算化会计系统和/或其他相关电算化系统的语言使用通知。
3. 企业须按照以下步骤向 **会计与审计监管机构（AAR）** 提交通知：

   **步骤 1**: 企业须在**会计与审计监管机构（AAR）**的电子申报系统中创建一个帐户才能使用通知功能（如果贵企业已经在**会计与审计监管机构（AAR）**的电子申报系统中拥有一个帐户，请使用现有帐户）。

   **步骤 2**: 企业须先完成一般信息（对于刚刚在电子申报系统中创建新账户的企业），然后保存。

   **步骤 3**: 点击**会计与审计监管机构（AAR）**的电子申报系统中的"使用语言通知"功能，然后填写更多信息并下载通知表格和完整的语言使用信息，指定系统名称、公司名称和根据**会计与审计监管机构（AAR）**的样本信函产生它的国家和计算机化会计系统中使用的语言，然后通过电子申报将信件发回。

企业须妥善保管原通知函，以备日后由 **会计与审计监管机构（AAR）** 进行合规检查。

任何在计算机化会计系统和/或其他相关会计系统中使用英语而未在上述截止日期前通知会计与审计监管机构的企业将受到 2020 年 6 月 1 日第 79 OrNKr.BK 号关于违反会计与审计法的临时罚款次级法令规定的处罚。

对此，请所有企业业主知悉并高效遵守本指示。

**总局长**

(签名&盖章)

**Bou Tharin**

要获取有关会计与审计专业和领域的最新信息，

请加入 Telegram 组 **Accounting and Auditing Regulator**

*Unofficial translation by GMAC*